**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សារលិខិតរំលែកទុក្ខ

## ជូនចំពោះ
## ក្រុមគ្រួសារយោធិនពលី និងយោធិនរងរបួស

ខ្ញុំ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានសេចក្តីរន្ធត់ចិត្តក្តុកក្តួលក្រៃលែងបន្ទាប់ពីបានទទួលដំណឹងអំពីឧបទ្ទវហេតុផ្ទុះគ្រាប់នៅយោធភូមិភាគទី៣ ក្នុងខេត្តកំពង់ស្ពឺ កាលពីរសៀលថ្ងៃសៅរ៍ ទី២៧ ខែមេសា ឆ្នាំ២០២៤ ដែលបានបង្កឱ្យយោធិនចំនួន ២០នាក់បានពលីជីវិត និងយោធិនមួយចំនួនទៀតបានរងរបួស។

ក្នុងឱកាសប្រកបដោយភាពក្រៀមក្រំជាអនេកនេះ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវសេចក្តីសោកស្តាយយ៉ាងធំធេង ចំពោះក្រុមគ្រួសារនៃជនរងគ្រោះទាំងអស់ និងសូមចូលរួមរំលែកមរណទុក្ខយ៉ាងក្រៀមក្រំបំផុតជាមួយក្រុមគ្រួសារនៃយោធិនពលី ក្នុងឧបទ្ទវហេតុដ៏សោកសង្រេងនេះ។

យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក សូមមេត្តាតាមជួយថែរក្សាយោធិនរងរបួសទាំងអស់ឆាប់បានជាសះស្បើយ។

ជាមួយគ្នានេះ យើងខ្ញុំទាំងអស់គ្នា ក៏សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធរបស់យោធិនពលីទាំងអស់សូមបានទៅសោយសុខក្នុងឋានសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **ក្រុមគ្រួសារនៃយោធិនពលីទាំងអស់** ទទួលនូវការចូលរួមរំលែកទុក្ខដ៏ក្រៀមក្រំនេះ និងការស្រឡាញ់រាប់អានយ៉ាងជ្រាលជ្រៅពីយើងខ្ញុំ។

ថ្ងៃច័ន្ទ ៦រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ហេង សួរ**